រាជរដ្ឋាភិបាលកម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

Council for the Development of Cambodia

ព្រះរាជាណាចក្រកម្ពុជា

Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation-Religion-King

# សេចក្ដីប្រកាសព័ត៌មាន

នាព្រឹកថ្ងៃចន្ទ ១កើត ខែកត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅវិមានសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មានរៀបចំវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩។ វេទិកានេះ មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ សមាជិក-សមាជិការាជរដ្ឋាភិបាល តំណាងអង្គទូតប្រទេសនានាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត មន្ត្រីរាជការ កម្លាំងប្រដាប់អាវុធ តំណាងដៃគូអភិវឌ្ឍន៍និងតំណាងអង្គការអន្តរជាតិ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រីតំណាងវិស័យឯកជន ព្រមទាំងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ ដែលមានចំនួនប្រមាណ ១,២០០នាក់។ ក្រោមគំនិតផ្ដួចផ្ដើមប្រកបដោយគតិបណ្ឌិតវែងឆ្ងាយរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយគិតចាប់តាំងចាប់បដិសន្ធិឡើងកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩មក វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជននេះ បន្តមានអត្ថិភាពចំនួន ២៤ ឆ្នាំ និងត្រូវបានចាត់ទុកថាជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបើកទូលាយដែលរាល់សេចក្ដីសម្រេចនានានៃវេទិកាមានអានុភាពជាសេចក្ដីសម្រេចរបស់គណៈរដ្ឋមន្ត្រី។

ដោយឡែកវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩នេះ គឺជាវេទិកាលើកដំបូងបន្ទាប់ពីប្រទេសកម្ពុជាបានចាកផុតពីការរាតត្បាតដោយសារជំងឺកូវីដ-១៩ និងបន្ទាប់ពីរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ត្រូវបានបង្កើតនិងក្រោមមគ្គុទេសដឹកនាំរបស់ **សម្ដេចបវរធិបតី ហ៊ុន ម៉ាណែត** ដែលជា **នាយករដ្ឋមន្ត្រី**។

ការសម្រេចរៀបចំវេទិកាឡើងវិញនេះ សមស្របទៅនឹងបរិការណ៍ដែលកម្ពុជាកំពុងបន្តលើកកម្ពស់និងជំរុញការកែលម្អបរិយាកាសធុរកិច្ច ដើម្បីជំរុញការអភិវឌ្ឍវិស័យឯកជន ដើម្បីចូលរួមកសាងភាពធន់នៃខឿនសេដ្ឋកិច្ចជាតិ និងពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា បន្ទាប់ពីកម្ពុជាបានយកឈ្នះទាំងស្រុងលើសមរភូមិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ព្រមទាំងបានស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ប្រកបដោយសុវត្ថិភាព និងភាពរឹងមាំ។

ខ្លឹមសារស្នូលនៃវេទិកា គឺការពិនិត្យរួមគ្នារវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន ទៅលើវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញនាពេលកន្លងមកតាមរយៈវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៨ និងជាបន្តបន្ទាប់សំដៅ÷

- *ចូលរួមជំរុញការអភិវឌ្ឍវិស័យឯកជន តាមរយៈការបង្កើនកិច្ចសន្ទនា*
- *សហការរវាងរាជរដ្ឋាភិបាលនិងផ្នែកឯកជនដោយមានការតាមដានវឌ្ឍនភាពនៃសកម្មភាពអភិវឌ្ឍន៍ផ្នែកឯកជន, ធុរកិច្ច និងការវិនិយោគ*
- *ពង្រឹងភាពប្រកួតប្រជែងរបស់ព្រះរាជាណាចក្រកម្ពុជា*
- *ចូលរួមធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ និង*
- *ធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគ តាមរយៈការស្វែងរកដំណោះស្រាយសម្រាប់បញ្ហាជាកង្វល់របស់ធុរជននិងការវិនិយោគ ដែលបាននិងកំពុងបណ្តាក់ទុននៅកម្ពុជា។*

ជាកិច្ចចាប់ផ្តើមនៃវេទិកា **ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី** អនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (**ក.អ.ក.**) និងក្នុងនាមជាប្រធានគណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន បានរាយការណ៍អំពីការរៀបចំយន្តការ, ការសម្របសម្រួល និងអំពីវឌ្ឍនភាពទូទៅនៃក្រុមការងារទាំង១៤ ជូនអង្គវេទិកា ដោយសមាសភាពក្រុមការងារទាំង ១៤ នេះ មាន÷ *(១).ក្រុមការងារកសិកម្មនិងកសិឧស្សាហកម្ម “ក”, (២).ក្រុមការងារទេសចរណ៍ “ខ”, (៣).ក្រុមការងារកម្មន្តសាស និងសហគ្រាសធុនតូចនិងមធ្យម និងសេវា “គ”, (៤).ក្រុមការងារនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច “ឃ”, (៥).ក្រុមការងារសេវាធនាគារ និងហិរញ្ញវត្ថុ “ង”, (៦).ក្រុមការងារដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ “ច”, (៧).ក្រុមការងារផលិតកម្មកែច្នៃសម្រាប់ការនាំចេញនិងកិច្ចសម្រួលពាណិជ្ជកម្ម “ឆ”, (៨).ក្រុមការងារទំនាក់ទំនងវិជ្ជាជីវៈ “ជ”, (៩).ក្រុមការងារស្រូវ-អង្ករ “ឈ”, (១០).ក្រុមការងារថាមពល និងធនធានរ៉ែ “ញ”, (១១).ក្រុមការងារអប់រំ “ដ”, (១២).ក្រុមការងារសុខាភិបាល “ឋ”, (១៣).ក្រុមការងារសំណង់ និងអចលនទ្រព្យ “ឌ” និង (១៤).ក្រុមការងារផ្នែកសេវាកម្មហិរញ្ញវត្ថុមិនមែនធនាគារ “ឍ”។*

ជាមួយគ្នានេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក.អ.ក.** បានយកឱកាសនេះសម្តែងនូវកត្តញ្ញូតាធម៌និងអំណរគុណដ៏ជ្រាលជ្រៅបំផុតគោរពជូនចំពោះ **សម្តេចតេជោអតីតនាយករដ្ឋមន្ត្រី** ដែលជាស្ថាបនិកនៃយន្តការនេះ និងជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមក្នុងការដឹកនាំវេទិកាកន្លងៗមក ព្រមទាំងបានផ្តល់នូវចក្ខុវិស័យជាយុទ្ធសាស្ត្រ វិធានការ និងការសម្រេចដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិត សំដៅលើកកម្ពស់បរិស្ថានធុរកិច្ចនិងវិនិយោគ និងពង្រឹងតួនាទីរបស់វិស័យឯកជន ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ បង្កើតការងារ និងពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គមជូនដល់ប្រជាពលរដ្ឋ។

បន្ថែមពីនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក.អ.ក.** ក៏បានសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅនិងស្ញើចសរសើរដល់ស្នាដៃដ៏ប៉ិនប្រសប់របស់ **ឯកឧត្តមកិត្តិបរិរក្សបណ្ឌិត គាត ឈន់** និង **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ដែលបានដើរតួនាទីជាអ្នកសម្របសម្រួលវេទិកានេះកន្លងមក ព្រមទាំង **ឯកឧត្តម សុខ ចិន្តាសោភា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** និងជាអតីតអគ្គលេខាធិការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ដែលបានជួយសម្របសម្រួលនិងគាំទ្រគ្រប់បែបយ៉ាងក្នុងដំណើរការនៃវេទិកានេះ តាំងពីដើមរៀងមករហូតដល់វេទិកា លើកទី១៨។

ដោយឡែកតំណាងផ្នែកឯកជន ដែលមាន **អ្នកឧកញ៉ា គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា, **ឧកញ៉ា លូ ម៉េង** តំណាងក្រុមការងារផ្នែកទេសចរណ៍ “ក្រុម ខ”, **ឧកញ៉ា ស្វ ឌួន** តំណាងក្រុមការងារផ្នែក

ដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ"ក្រុម ច" និង**ឧកញ៉ាបណ្ឌិត ឈាង សុធី** តំណាងក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ"ក្រុម ជ" ក៏បានរាយការណ៍អំពីលទ្ធផលនៃកិច្ចពិភាក្សាទាំងឡាយរបស់ក្រុមការងារតាមវិស័យក្នុងផ្នែកឯកជន និងព្រមទាំងបានធ្វើនូវបទអន្តរាគមន៍ស្តីពីបញ្ហាប្រឈមរបស់វិស័យឯកជនផងដែរ។ ជាមួយគ្នានេះ តំណាងផ្នែកឯកជន បានអបអរសាទររាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដ៏ធំធេងនានាដែលកម្ពុជាសម្រេចបានកន្លងមក ដោយបានអះអាងថាស្ថានភាពរបស់កម្ពុជានៅពេលនេះ គឺខុសគ្នាឆ្ងាយខ្លាំងណាស់ ដោយកម្ពុជាគឺជាប្រទេសដែលបានរក្សាកំណើនសេដ្ឋកិច្ចរបស់ខ្លួនក្នុងអំឡុងពេលពីរទសវត្សចុងក្រោយ និងបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេស ដែលមានកំណើនផលិតផលក្នុងស្រុកសរុប (**ផ.ស.ស.**) ឈានមុខគេនៅក្នុងពិភពលោក។ ចំពោះវិហ្វូវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា មានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែត្រូវបានថមថយខ្លះទៅវិញនៅក្នុងអំឡុងនៃវិបត្តិសកលនៃជំងឺកូវីដ-១៩។ ការបណ្តាក់ទុនក្នុងស្រុក គួបផ្សំនឹងវិហ្វូវិនិយោគផ្ទាល់ពីបរទេសនេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងបង្កើតការងារជូនប្រជាជនកម្ពុជា។ កំណើនសេដ្ឋកិច្ចនេះគឺជាលទ្ធផលនៃការរួមចំណែកយ៉ាងសំខាន់ពីវិស័យឯកជន។

ជាមួយគ្នានេះ តំណាងផ្នែកឯកជន ក៏បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលដែលបានដាក់ចេញនូវគោលនយោបាយនិងវិធានការថ្មីៗកន្លងមក ដែលតាមរយៈនេះ វិស័យឯកជនទទួលបាននូវការលើកទឹកចិត្ត និងកិច្ចសម្រួលដ៏សម្បើមនៅក្នុងសកម្មភាពធុរកិច្ចរបស់ខ្លួន ជាពិសេសការលើកទឹកចិត្តវៃឆ្លាតដែលមានចែងនៅក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសអោយប្រើ កាលពីខែតុលា ឆ្នាំ២០២១ កន្លងទៅ និងដែលមាននៅក្នុងច្បាប់និងបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ការដាក់ឱ្យអនុវត្តនូវវិធានការថ្មីៗកន្លងមក គឺជាតឹកតាងថ្មីមួយទៀតនៃប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃភាពជាដៃគូសន្ទនារវាងរាជរដ្ឋាភិបាល-ផ្នែកឯកជន ដែលនេះបានបង្ហាញអំពីការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលចំពោះវិនិយោគិន និងធុរជន។ ទន្ទឹមនឹងនេះដែរ តំណាងផ្នែកឯកជនបានសម្តែងនូវសេចក្តីសោមនស្សចំពោះរាជរដ្ឋាភិបាលដែលបានសម្រេចទទួលស្គាល់ជាផ្លូវការនូវសមាសភាពក្រុមការងារទាំង១៤ ផ្នែកឯកជននៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន តាមរយៈសេចក្តីសម្រេចលេខ ១៣០ សសរ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ហើយសមាសភាពក្រុមការងារទាំង១៤នេះ គឺជាយន្តការសន្ទនារវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃបណ្តាក្រសួង-ស្ថាប័ន និងតំណាងផ្នែកឯកជនទៅតាមវិស័យ។

ក្នុងសុន្ទរកថារបស់ខ្លួននាឱកាសដ៏មហោឡារិកនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** បានសម្តែងនូវកតញ្ញូតាធម៌និងការដឹងគុណដ៏ជ្រាលជ្រៅបំផុតគោរពជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា** ដែលជាស្ថាបនិក និងដែលតែងតែដឹកនាំវេទិកានេះជាបន្តបន្ទាប់គិតចាប់ពីវេទិកាលើកទី១ រហូតដល់វេទិកាលើកទី១៨ ដោយកន្លងមក **សម្តេចតេជោអតីតនាយករដ្ឋមន្ត្រី** ធ្លាប់បានផ្តល់នូវចក្ខុវិស័យ យុទ្ធសាស្ត្រ វិធានការ និងការសម្រេចដ៏ខ្ពង់ខ្ពស់និងប្រកបដោយគតិបណ្ឌិត ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិស្ថានធុរកិច្ច និងការវិនិយោគនៅកម្ពុជា និងពង្រឹងវិស័យឯកជនឱ្យកាន់តែមានជីវភាព និងភាពជាម្ចាស់ក្នុងតួនាទីជាក្បាលម៉ាស៊ីននៃសេដ្ឋកិច្ច។

ជាក់ស្តែង យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនទាំង១៨ កន្លងមក បានរួមចំណែកយ៉ាងសំខាន់ដល់ការកែលម្អបរិយាកាសនៃការធ្វើធុរកិច្ច និងការវិនិយោគនៅកម្ពុជា ជាបន្តបន្ទាប់។

យោងតាម Business Ready នៃធនាគារពិភពលោក, កម្ពុជាបានកាត់បន្ថយ ចំណាយចាប់ផ្តើមធុរកិច្ចពី ៥៣% នៃចំណូលសម្រាប់មនុស្សម្នាក់នៅឆ្នាំ២០១៩ មកត្រឹម ២២% នៅឆ្នាំ២០២២; ចំណាយឡូជីស្ទិកត្រូវបានកាត់បន្ថយពី ៣៣% នៃ ផសស នៅឆ្នាំ២០១៥ មកត្រឹម ២៦% នៃ ផសស នៅឆ្នាំ២០២២ និងថ្លៃអគ្គិសនីសម្រាប់ឧស្សាហកម្ម ត្រូវបានកាត់បន្ថយពី ១៦,៧ សេន/មួយគីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០១៧ មកត្រឹម ១៣,៧ សេន/មួយគីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០២២។ ទោះបីវឌ្ឍនភាពនេះ, បើមើលមួយភ្លែតទៅឃើញហាក់ដូចជានៅតិចតួច ក៏ប៉ុន្តែយើងទាំងអស់គ្នាបានខិតខំធ្វើការជាប្រចាំជាមួយនឹងឆន្ទៈមោះមុត តាមទិសស្លោក “កែទម្រង់-រស់, មិនកែទម្រង់-ស្លាប់” នៅក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត, ភាពឈ្លាសវៃ, ភាពប្រាកដនិយម និងភាពម៉ឺងម៉ាត់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

ផ្អែកលើមូលដ្ឋាននៃសាវតារួមនេះ ការរៀបចំឡើងនូវវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាពេលនេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលក្នុងការបន្តនូវប្រពៃណីដ៏បវរពីរាជរដ្ឋាភិបាលនីតិកាលមុន សំដៅជួយគាំទ្រជំរុញ និងលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន។ មួយវិញទៀត, វេទិកាលើកទី ១៩ នេះ ក៏ជាជំហានប្រវត្តិសាស្ត្រមួយទៀត នៃការចេញដំណើរឆ្ពោះទៅកាន់ **“ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០”** ប្រកបដោយភាពជឿជាក់ និងថាមពលរបស់រាជរដ្ឋាភិបាល អាណត្តិទី៧ ដូចបានគូសរំលេចយ៉ាងក្បោះក្បាយក្នុងបទអន្តរាគមន៍ដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល** មុននេះបន្តិច។ នៅក្នុងដំណើរការរៀបចំវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ នេះ, ក្រុមការងារតាមផ្នែកដែលបច្ចុប្បន្នមានចំនួន ១៤ បានជួបប្រជុំនិងប្រមូលសរុបការងាររៀងខ្លួន ដោយបានពិភាក្សាលើបញ្ហាប្រឈម និងស្នើឡើងនូវវិធានការអាទិភាពប្រមាណជិត ២០០ សម្រាប់រាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។ ជាការកត់សម្គាល់, វិធានការទាំងនោះ មានលក្ខណៈចម្រុះ ពោល គឺមានតូច, មានធំ, មានទូទៅ និងជាក់លាក់តាមវិស័យ, មានជាបញ្ហារយៈពេលខ្លី និងមធ្យម, និងមានខ្លះទៀត ជាបញ្ហារួមអន្តរវិស័យ (Cross-cutting)។ បញ្ហាប្រឈមភាគច្រើន ត្រូវបានឯកភាពគ្នាដោះស្រាយរួចរាល់នៅក្នុងកម្រិតក្រុមការងារ។

ប៉ុន្តែ ក៏មានបញ្ហាចំនួន ២៣ ត្រូវបានសម្រេចបង្វែរជូនទៅក្រុមការងារផ្នែកផ្សេង ដែលមានសមត្ថកិច្ចសមស្របជាង។ ជាមួយគ្នានេះ, វិធានការដែលមានលក្ខណៈអន្តរវិស័យ និងអន្តរស្ថាប័នប្រមាណ ១៤ ត្រូវបានបញ្ជូនបន្តមកគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចាត់ការបន្ត។ ជាលទ្ធផល, គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំពាក់ព័ន្ធជាបន្តបន្ទាប់, ទាំងកិច្ចប្រជុំរួម និងដាច់ដោយឡែក, និងបានផ្តល់គោលការណ៍សម្រាប់ដោះស្រាយបញ្ហាទាំងនោះរួចរាល់ ហើយដែលការខិតខំដោះស្រាយបណ្តាបញ្ហាប្រឈម ប្រកបដោយស្មារតីយោគយល់ខ្ពស់ ក្នុងកម្រិតក្រុមការងារបង្ហាញពីភាពម្ចាស់ការ និងប្រសិទ្ធភាពខ្ពស់នៃក្រុមការងារតាមផ្នែក។ យន្តការក្រុមការងារតាមផ្នែក ក៏បានក្លាយជាវេទិកាកម្រិតបច្ចេកទេសជាន់ខ្ពស់ ដ៏មានសារៈសំខាន់មួយ សម្រាប់ពន្យល់បកស្រាយលើទិដ្ឋភាពនីតិវិធី

និងការអនុវត្តនៃវិធានការគោលនយោបាយរបស់រដ្ឋាភិបាល ដែលពុំទាន់មានភាពច្បាស់លាស់សម្រាប់វិស័យឯកជន, នេះម្យ៉ាង និងម្យ៉ាងទៀត, យន្តការនេះ ក៏ផ្តល់ឱកាសសម្រាប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អាចស្វែងយល់កាន់តែស៊ីជម្រៅលើបញ្ហាប្រឈមជាក់លាក់តាមវិស័យដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ការណ៍នេះ បានអនុញ្ញាតឱ្យក្រសួង ស្ថាប័ននៃរដ្ឋាភិបាលមានលទ្ធភាពកាន់តែខ្ពស់ក្នុងការដាក់ចេញនូវវិធានការបន្ថែមឱ្យចំគោលដៅ និងមានប្រសិទ្ធភាព ឬផ្តល់ភាពទន់ភ្លន់ក្នុងការអនុវត្តវិធានការមានស្រាប់មួយចំនួន សំដៅដោះស្រាយកង្វល់នានារបស់វិស័យឯកជន។

យ៉ាងណាមិញ នៅមានសេសសល់កិច្ចការមួយចំនួន ពុំទាន់ទទួលបាននូវដំណោះស្រាយ ឬការឆ្លើយតបពេញលេញនៅឡើយ ដែល **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានរាយការណ៍ជូន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** នូវសំណូមពររបស់វិស័យឯកជន ចំនួន១០ ចំណុច ដើម្បីទទួលបានអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ពីសំណាក់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ទាំងក្នុងលក្ខណៈជាគោលការណ៍ និងទាំងការដាក់ចេញជាវិធានការជាក់ស្តែង សម្រាប់យកទៅអនុវត្តបន្ត។ ចំណុចទាំង ១០ នោះគឺពាក់ព័ន្ធនឹង÷

**ទី១- ការសម្រួលបរិយាកាសធុរកិច្ច និងការវិនិយោគ** តាមរយៈការផ្តល់ការសម្រួលក្នុងការបំពេញកាតព្វកិច្ចគណនេយ្យ និងសវនកម្ម; ការលើកកម្ពស់តម្លាភាពនៃការងារប្រយុទ្ធប្រឆាំងនឹងផលិតផលក្លែងក្លាយ; ការបន្តជំរុញការរៀបចំការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ការគាំទ្របន្ថែមដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម; និងការចូលរួមរបស់វិស័យឯកជន ក្នុងការរៀបចំបទដ្ឋានគតិយុត្ត។

**ទី២- ការសម្រាលបន្ទុកលើអនុលោមភាព** តាមរយៈការជំរុញការអនុវត្តយន្តការ ក្រុមការងារអធិការកិច្ចអន្តរក្រសួង, ការបន្តជំរុញការអភិវឌ្ឍជំនាញ និងផលិតភាព របស់កម្មករ-និយោជិត និងការពង្រឹងការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ។

**ទី៣- ការសម្រួលធុរកិច្ចនៅក្រោមដែនសមត្ថកិច្ចពន្ធដារ** តាមរយៈការបន្តគោលការណ៍មិនយកពន្ធ; ការលុបការបង់ភាស៊ី និងការបង់កម្រៃផ្សេងៗ; ការអនុគ្រោះបន្ថែម ពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យ; ការកែសម្រួលការប្រមូលពន្ធលើដីធ្លីមិនប្រើប្រាស់; ការសម្រួល និងការពង្រីកវិសាលភាពនៃការអនុគ្រោះពន្ធក្នុងវិស័យកសិកម្ម; ការផ្តល់ការអនុគ្រោះ ពិសេសសម្រាប់វិស័យទេសចរណ៍ក្នុងខេត្តសៀមរាប ការលើកទឹកចិត្តផ្សេងទៀត; និងការបន្តជំរុញកិច្ចការកែទម្រង់រដ្ឋបាលសារពើពន្ធ។

**ទី៤-ការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម នៅក្រោមដែនសមត្ថកិច្ចគយ** តាមរយៈការសម្រួលវិធាន និងនីតិវិធីក្នុងការបញ្ចេញទំនិញ ការលើកកម្ពស់ប្រសិទ្ធភាពសេវាគយ និងការបន្តជំរុញការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ឱ្យកាន់តែច្រើន; ការអនុញ្ញាតឱ្យមានការផ្តល់សេវាធ្វើការបន្ថែមម៉ោងរបស់មន្ត្រីគយ នៅពេលយប់; ការបន្តជំរុញការបណ្តុះបណ្តាល និងការផ្តល់អាជ្ញាបណ្ណជើងសារគយ; និងការពង្រឹងការគ្រប់គ្រងលើការនាំចូលដោយខុសច្បាប់នូវ សាច់ជ្រូកបង្កក, មាន់, ស៊ុត និងត្រី ជាដើម។

**ទី៥- ការលើកកម្ពស់ការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ** តាមរយៈការដំឡើង កម្រិតទម្ងន់រថយន្តដឹកទំនិញ។

**ទី៦-ការស្តារ និងការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍** តាមរយៈការដាក់ដំណើរការក្រុមប្រឹក្សាទេសចរណ៍ ដើម្បីលើកកម្ពស់កិត្តិនាមកម្ពុជា; ការសម្រួលដល់ទេសចរក្នុងការទស្សនាខេត្តសៀមរាប ដោយផ្សារភ្ជាប់នឹងការតភ្ជាប់ជើងហោះហើរ និងការសម្រួលផ្នែកទិដ្ឋាការ; ការលើកកម្ពស់បដិសណ្ឋារកិច្ចតាមច្រកទ្វារព្រំដែន; ការគិតគូរពង្រីកវិសាលភាពបណ្ណព្រំដែន; និងការផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប; ព្រមទាំងការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់វិស័យនេះ។

**ទី៧-ការជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម** តាមរយៈការកសាងប្រព័ន្ធផលិតគ្រាប់ពូជសុទ្ធលើប្រភេទស្រូវផ្ការំដួល និងសែនក្រអូប; ការពង្រឹងគុណភាពនៃការនាំចូលគ្រាប់ពូជបន្លែ និងការផលិតពូជបន្លែក្នុងស្រុក; ការជំរុញការនាំចេញអង្ករ និងស្វាយចន្ទី; ការរៀបចំសហគមន៍កសិកម្ម; ការរៀបចំបង្កើតច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការអនុវត្តយន្តការលើកទឹកចិត្តក្នុងវិស័យនេះ។

**ទី៨-ការជំរុញការចូលរួមចំណែករបស់វិស័យធនាគារ ដើម្បីបង្កើនលទ្ធភាពទទួលបានឥណទានសម្រាប់វិស័យឯកជន ដោយរក្សាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ** តាមរយៈ ការរក្សាអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិន (Capital Conservation Buffer) ដែលមានភាពអនុគ្រោះ; ការអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ; ការបន្តអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ ក្នុងកម្រិតសមស្រប និងការបន្តលើកទឹកចិត្ត គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឱ្យរៀបចំឥណទានឡើងវិញ។

**ទី៩-ការជំរុញការអភិវឌ្ឍវិស័យរ៉ែ និងថាមពល** តាមរយៈការកែលម្អការគ្រប់គ្រង និងការជំរុញលើកទឹកចិត្តការធ្វើអាជីវកម្ម និងការនាំចេញថ្មអារ; ការធ្វើសាមញ្ញកម្មនីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់ការនាំចេញ, និងការបន្តជំរុញការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូល។

**ទី១០-ការគាំទ្រដល់វិស័យសំណង់ និងអចលនទ្រព្យ** តាមរយៈការបន្តអនុវត្តវិធានការជាកញ្ចប់រួមមាន បន្តពន្យារពេលការអនុវត្ត និងការបង្កើនរយៈពេលនៃការបង់ពន្ធជាកញ្ចប់ តាមដំណាក់កាល; ការលើកទឹកចិត្តផ្នែកសារពើពន្ធ និងការលើកលែងការផាកពិន័យនានា; ការបន្ធូរបន្ថយកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុ ឱ្យរងសវនកម្មឯករាជ្យ និងការផ្តល់សិទ្ធិឱ្យជនបរទេសអាចកាន់កាប់អចលនទ្រព្យ ជាដើម។

នៅក្នុងសុន្ទរកថានិងប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះតំណាងផ្នែកឯកជន ដែលបានចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជាជាមួយរាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានស្វាគមន៍ចំពោះការលើកឡើងដោយស្មោះត្រង់ និងក្នុងន័យស្ថាបនាពាក់ព័ន្ធនឹងបញ្ហាប្រឈមនានា ក្នុងនាមជាដៃគូសន្ទនាដែលមិនអាចខ្វះបាន និងបានបំពេញឱ្យគ្នាទៅវិញទៅមកក្នុងដំណើរឆ្ពោះទៅកាន់សមាហរណកម្មនៅក្នុងតំបន់ដែលកាន់តែទូលំទូលាយ។ ក្នុងន័យនេះ អនុសាសន៍គោលនយោបាយរបស់តំណាងផ្នែកឯកជន ពិតជាមានសារៈសំខាន់ និងជាធាតុចូលសម្រាប់រាជរដ្ឋាភិបាល ក្នុងការសម្រេចជាលក្ខណៈគោលនយោបាយក្នុងការដឹកនាំ។ ដោយហេតុនេះ ទើបរាជរដ្ឋាភិបាលបានបង្កើតឱ្យមានវេទិកានេះឡើង។

បន្ថែមលើនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានជម្រាបអ្នកចូលរួមទាំងអស់ ជាពិសេសចំពោះដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជនថាពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការដាក់ចេញនិងជំរុញការអនុវត្តប្រកបដោយឆន្ទៈមោះមុតឥតរាថយក្នុងការដាក់ចេញនូវកញ្ចប់វិធានការកែទម្រង់ នៅក្រោម**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** ស្របតាមបាវចនា " **ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព**" និងការអនុវត្តអភិក្រម ៥ យ៉ាង "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" និងអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ** (Dynamics of Stakeholder System)" សំដៅការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។ ទន្ទឹមនឹងនេះ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** កំណត់យកអាទិភាពគន្លឹះ ៥ គឺ "**មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យា**" ជាពិសេសគឺ "**បច្ចេកវិទ្យាឌីជីថល**" សម្រាប់ឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ចនិងសង្គមកម្ពុជា។

ជាការឆ្លើយតបទៅនឹងសំណូមពរ និងបញ្ហាប្រឈមដែលបានលើកឡើងដោយតំណាងផ្នែកឯកជន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានសម្រេចដ៏ខ្ពង់ខ្ពស់ ដាក់ចេញនូវវិធានការមួយចំនួន ដែលនឹងមានប្រកាសជូនតាមរយៈសេចក្តីជូនដំណឹងស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន នាពេលឆាប់ៗខាងមុខ។